## អញ្ជើញចូលរួមបុណ្យសព

សូមអញ្ជើញពុទ្ធបរិស័ទ អស់លោក-លោកស្រី និងសប្បុរសជនទាំងអស់ ចូលរួមបុណ្យសព**មហាឧបាសកអ៊ុងខាន់** ដែលបានទទួលអនិច្ចកម្មកាលពីថ្ងៃ១កើត ខែបុស្ស ឆ្នាំវក ឆស័ក ពុទ្ធសករាជ២៥៤៨ ត្រូវគ្នានឹងថ្ងៃច័ន្ទ ទី១០ ខែមករា ២០០៥, វេលាម៉ោង ០៦:០០ព្រឹក ក្នុងព្រះជន្មាយុ១០៤ ។

<u>ទីកន្លែង</u>: **Pieson’s Funeral Service, 4121 – 17 Avenue S.E., Calgary, AB, Tel: 235-3602**

*ថ្ងៃអង្គារ ទី១១ មករា ២០០៥*

- ម៉ោង ០៦ ល្ងាច= ជួបជុំកូនចៅ ញាតិមិត្ត ពុទ្ធបរិស័ទ និងសប្បុរសជនទាំងអស់ ។
- ម៉ោង ០៦:៣០ នមស្សការព្រះរតនត្រ័យ សមាទានទានសីល ព្រះសង្ឃសូត្រព្រះអភិធម្ម

*ថ្ងៃសៅរ៍ ទី១៥ មករា ២០០៥*

- ម៉ោង១២:០០ថ្ងៃ = ជួបជុំកូនចៅ ញាតិមិត្ត ពុទ្ធបរិស័ទ និងសប្បុរសជនទាំងអស់ ។
- ម៉ោង១២:៣០-១:៣០=នមស្សការព្រះរតនត្រ័យ សមាទានសីល និមន្តព្រះសង្ឃសូត្រព្រះអភិធម្ម។ អានជីវប្រវត្តិដោយសង្ខេប និងសំវេជនីយកថា។ ភ្ញៀវទាំងអស់ គោរពវិញ្ញាណក្ខន្ធសព និងពិធីដង្ហែសពទៅបូជា។

*ថ្ងៃអាទិត្យ ទី១៦ មករា ២០០៥*(ធ្វើបុណ្យនៅវត្តខ្មែរសាមគ្គីកាលហ្គារី) 7011 Ogden Rd., S.E.

- ម៉ោង០៩:៣០= ជួបជុំកូនចៅ ញាតិមិត្ត ពុទ្ធបរិស័ទ និងសប្បុរសជនទាំងអស់ ។
- ម៉ោង១០:៣០= នមស្សការព្រះរតនត្រ័យ សមាទានសីល រាប់បាតបង្សុកុល និងវេរចង្ហាន់ប្រគេនព្រះសង្ឃ ។
- ម៉ោង១១:៥០= ព្រះសង្ឃសំដែងព្រះធម៌ទេសនារឿង “ **កតញ្ញូតាធម៌**” ។ ភ្ញៀវទាំងអស់ស្រស់ស្រូបអាហាររួមគ្នា ។





## IN LOVING MEMORY

I, Oung Khath, and my family mourn the death of my father, **Mr. Oung Khan**, who passed away on January 10, 2005 at 6:00 AM. He is 104 years old. I would like to invite you, Venerable Monks, Buddhists, friends of the Cambodian Community and guests to come and join us *In Loving Memory* to be scheduled as follow:

<u>Place</u>: **Pieson’s Funeral Service, 4121 – 17 Avenue SE., Calgary, AB, Tel: 235-3602**

***Tuesday, January 11, 2005***

- 06:00 PM Arrival of monks, relatives and guests.
- 06:30 PM Worship Triple Gem, observe precepts and monks chant Abhidhamma Blessings.

***Saturday, January 15, 2005***

- 12:00 AM Arrival of monks, relatives and guests.
- 12:30-1:30 AM Worship Triple Gem, observe precepts, monks chant Abhidhamma Blessings. Reading his history background and commemorating speech. All relatives and guests pay their last respect to **Mr. Oung Khan** and proceed to the crematorium.

***Sunday, January 16, 2005***

**<u>Place</u>**: At Khmer Buddhist Temple of Calgary
7011 Ogden Rd., S.E.

- 09:00 AM Arrival of relatives and guests.
- 10:30 AM Worship Triple Gem, observe precepts, offer alms food to monks and monks chant Abhidhamma Blessings.
- 11:50 AM A short preaching about the “**Child’s Gratitude**”. All relatives and guests have lunch together.

*For more information contact: Mr. Oung Khath, Home: 248-5497, Cell: 383-1784*

## **ប្រវត្តិរូបលោកអ៊ុង ខាន់** (ដោយសង្ខេប)

លោក ឪពុកអ៊ុង ខាន់ កើតនៅឆ្នាំ១៩០០ នៅភូមិធ្លកវៀន ឃុំធ្លកវៀន ខេត្តកំពង់ឆ្នាំង។ លោក ឪពុកជាកូនពៅគេបង្អស់ ក្នុងចំណោមបងប្អូន ប្រុស៣នាក់ និង ស្រី១នាក់ របស់លោកតាអ៊ុង និងលោកយាយណាក។ លោក ឪពុក ធ្លាប់បានសាង ព្រះផ្នួសជា បព្វជិតក្នុង ព្រះពុទ្ធសាសនា អស់រយះពេលជាច្រើន ព្រះវស្សា ហើយបន្ទាប់ពីលាចាកសិក្ខាបទ លោក ឪពុកបានរៀបអាពាពិពាហ៍ ជាមួយអ្នកម្ដាយឡេង ធុន។ គាត់ទាំងពីរចាប់ដៃគ្នារួមរស់ យ៉ាងសុខសាន្ត ប្រកបមុខរបររកស៊ី នៅក្នុងភូមិធ្លកវៀនបាន៣ឆ្នាំ រួចក៏នាំគ្នាមករស់នៅក្នុង ខេត្តពោធិសាត់ ដោយយល់ឃើញថាខេត្តពោធិសាត់សំបូរដីស្រែច្រើន ស្រួលធ្វើស្រែចំការ។ លោក ឪពុក ជាអ្នកស្លូត ត្រង់ក្នុង ស្រុកបាកាន ភូមិព្រៃផ្ដៅ ខេត្តពោធិសាត់។ លោក ឪពុក និងអ្នកម្ដាយមានបុត្រធីតា៥នាក់ ប្រុស៤ ស្រី១។ កូនទាំងអស់រាប់ពីបង គេបង្អស់មកមាន ដូចជាលោកអ៊ុង សាត, អ៊ុង ខុន, អ៊ុង ខាត់, អ៊ុង ឃុន និងប្អូន ស្រីក្រោយគេបង្អស់នាងអ៊ុង ធួក។

លោក ឪពុកធ្លាប់បានធ្វើស្រែបំរើសម្ដេចមុនីវង្ស ដោយសម្ដេច ប្រទានលុយពីរកាក់ក្នុងមួយថ្ងៃ នៅឯដំណាក់ ត្រពាំងជុង។ លោក ឪពុកបានបែកពី ប្រពន្ធ, កូនបួននាក់ និង ចៅជាច្រើននៅឯ ស្រុកខ្មែរចាប់តាំងពីឆ្នាំ ១៩៧៩មកម្លេះ។ ដោយសារពួកខ្មែរ ក្រហមវាយបំបែក លោក ឪពុកក៏សម្រេចចិត្តចាកចោល ស្រុក មករស់នៅជួបជុំជាមួយកូន (ខ្ញុំ) និងកូន ប្រសារបិន ហេង នៅឯជំរំអស់រយះពេល៦ឆ្នាំ ទើបចេញមករស់នៅឯ ប្រទេស កាណាដាជាមួយគ្នាក្នុងឆ្នាំ១៩៨៦ ។

នៅ ប្រទេសកាណាដា លោក ឪពុកថែទាំ និងផ្ដល់សេចក្ដីកក់ក្ដៅដល់កូនចៅទាំងអស់ និងទទួលការគោរពដ៏ខ្ពង់ខ្ពស់ពីសហគមខ្មែរក្នុងនាមជា ព្រឹទ្ធាចារ្យដែលមានវ័យចំណាស់ជាង គេ។ ក្រោយមកដោយសាររោគជរាព្យាធិ ហើយកូនចៅជាប់រវល់មមាញឹកនឹងការងារពេក ទើបលោក ឪពុកទៅរស់នៅក្នុងផ្ទះជរា(Nursing Home)នៅឆ្នាំ២០០១។ តែលោក ឪពុកបានទទួល ការទៅសួរសុខទុក្ខនិងថែទាំពីកូនចៅជារៀងរាល់ថ្ងៃ ឥតដាច់។ ពិតណាស់ លោក ឪពុកមានវ័យជរាខ្លាំង តែកំឡាំងពលំនិងការចងចាំ នៅមានជានិច្ច។ លោក ឪពុកអាចហូបបាយ ខ្លួនឯង ទៅបន្ទប់រង់តូចធំខ្លួនឯង ហើយចាំថ្ងៃខែឆ្នាំបានច្បាស់ ឥតភ្លេច ព្រមទាំងចាំឈ្មោះកូន ឈ្មោះចៅ និងមិត្តភក្តិទៀតផង។

ឥឡូវនេះ លោក ឪពុកបានចាកចោលយើងហើយ តែលោក ឪពុកបានបន្សល់ទុកនូវ គុណូបការគុណដ៏ធំធេងដល់យើងខ្ញុំទាំងឡាយ ។ សូមអរគុណនិងអរ ព្រះគុណ ។